## សិក្សាអត្ថបទរបស់លោកឈាន-វ៉ម

# អំពីការបាត់បង់ដែនដីកម្ពុជាក្រោម
# ទៅវៀតណាមក្នុងឆ្នាំ១៩៤៩

ដោយ សុទ្ធ-ប៉ូលិន ★ ថ្ងៃទី១៤ មិនា ២០០៦

មុនពេលលោកទទួលអនិច្ចកម្មនៅក្នុងឆ្នាំ១៩៩៩ លោកឈាន-វ៉ម អតីតរដ្ឋមន្ត្រីទី១ខ្មែរនៅក្នុងឆ្នាំ១៩៤៨ (កាលនោះលោកបន្តតំណែងពីទ្រង់ស៊ីសុវត្ថិ-យុត្តិវង្ស)... បានបន្សល់ទុកនូវឯកសារមួយយ៉ាងខ្លី មានតែ៨ទំព័រប៉ុណ្ណោះជាភាសាបារាំង ហើ-យដែលមានចំណងជើងដូចនេះ ៖

«រឿងបញ្ហាដែលគេហៅថា កូសាំងស៊ីន» ។ ប៉ុន្តែនឹងចូលដល់សាច់រឿង និងទីជំរៅរបស់ឯកសារ លោកឈាន-វ៉មបានធ្វើការព្រមានទុកមុនជាស្រេច ៖ «ថ្ងៃខែមួយចំនួន ព្រមទាំងសាច់រឿងដ៏ពិស្តារខ្លះៗ (កកន ៖ គួរឲ្យឆ្ងល់...បើមិនច្បាស់ទេ ម្ដេចហៅថាពិត?) ដែលលើកយកមកនិយាយជាសក្ខីភាពនេះ ត្រូវចាត់ទុកថាជាទង្វើប្រហាក់ប្រហែលស្រពិចស្រពិល (កកន ៖ លោកឈាន-វ៉មមានប្រសាសន៍ថាឯកសាររបស់គាត់គ្មានតម្លៃទេ... រឿងរ៉ាវទាំងអស់គាត់ចាំមិនច្បាស់)...ពីព្រោះដោយហេតុថា ៖

– ម៉្យាងព្រឹត្តិការណ៍បានកន្លងផុតទៅជាយូរយារណាស់មកហើយ (ពីខែមេសា១៩៤៩ មកខែមេសា១៩៩៩) ពោលគឺមានរយៈវេលា៥០ឆ្នាំ (កកន ៖ គម្លាតនៃពេ-លវេលាមានតែ៥០ឆ្នាំទេតើ ម្ដេចបានជាលោកឈាម-វ៉ម ដែលគាត់ទុកថាជាអ្នកស្នេហាជាតិខ្មែរ ភ្លេចរឿងរ៉ាវដ៏សំខាន់ជាងគេបំផុតនៅក្នុងជីវិតរបស់លោក គឺការបាត់បង់ទឹកដីកម្ពុជាក្រោមទៅវៀតណាម ? ធម្មតា ទោះជាគម្លាតមានរាប់ពាន់ឆ្នាំក៏ដោយ ក៏អ្នកស្នេហាជាតិតែងតែនឹករលឹកឃើញជានិច្ច ហើយតែងតែមានឯកសារប្រ-ចាំខ្លួនជានិច្ចកាល ស្ដីអំពីកាលៈទេសៈដ៏ពិស្តារនៃការបាត់បង់ទឹកដីរបស់ខ្លួន ។ អ្នកប្រាជ្ញចិត្តសាស្ត្រដ៏ល្បីល្បាញជាងគេនៅពិភពខាងលិច ហ្វ្រឺដ(Freud) បាននិយាយថា ៖ «ការភ្លេចភ្លាំងជាសញ្ញានៃការស្អប់ខ្ពើម L'oubli est un signe de l'inimitié គេមិនដែលភ្លេចអ្វីៗ ដែលគេជាប់ចិត្តស្រឡាញ់នោះទេ) ។

ជាបន្តមកទៀត លោកឈាន-វ៉មបានសរសេរថា ៖ «ហើយម៉្យាងវិញទៀត គឺបណ្ដាលមកពីកង្វះឯកសារដ៏សំខាន់ៗ (កកន ៖ ឯកសារនៃការបាត់បង់ទឹកដីកម្ពុជា

ក្រោម មានគរដឹកនៅប្រទេសបារាំង)... ឯកសារអស់ទាំងនេះ បានត្រូវបំផ្លិចបំផ្លាញអស់រលីងទៅហើយ ដោយពួកខ្មែរក្រហម ។ គឺជាការច្បាស់ណាស់ ក្រុមគ្រួសារខ្ញុំហើយនិងរូបខ្ញុំ បានត្រូវបង្ខំនៅថ្ងៃទី១៧មេសា១៩៧៥ ឲ្យបោះបង់ចោលផ្ទះសំបែងរបស់យើង ព្រមទាំងអ្វីៗទាំងអស់ ដែលនៅក្នុងនោះ (កកន ៖ គិតសព្វៗទៅ មេខ្មែរយៀកមិញដ៏កំពូល ឈាន-វ៉ម ដែលត្រូវជាគ្រូរបស់ប៉ុល-ពត កំពុងតែថ្វូរថាខ្លួនជាអ្នករងគ្រោះរបស់ខ្មែរក្រហមដែរ, ប្រហែលគ្នានឹងសេចក្តីតម្អូញរបស់មេខ្មែរយៀកមិញម្នាក់ទៀត គឺជួន-មុំ, ប្អូនថ្លៃរបស់ឈាន-វ៉ម ដែលបាននិយាយប្រាប់លោក William Shawcross នៅក្នុងឆ្នាំ១៩៧៩ នៅព្រំប្រទល់ដែនខ្មែរ-ថៃ ។ គួរជ្រាបថា កាលនោះ ជួន-មុមទើបរត់ចេញពីប៉ុល-ពត ជាមួយនិងគាត-ឈន់ ៖ «ខ្លួនខ្ញុំ (ជួន-មុម) បានប្រឆាំងនឹងគំនិតដែលថា យើងអាចកសាងប្រទេសមួយ ដោយមិនបាច់មានបញ្ញាជន...។ ខ្ញុំបានប្រឆាំងនឹងការដុតបំផ្លាញសៀវភៅឯកសារផងដែរ ។ ម៉្លោះហើយគេក៏បានកាត់ខ្ញុំចេញពីពួកមេក្រុមអ្នកដឹកនាំ (ខ្មែរក្រហម) ។ ពីឆ្នាំ១៩៧៧ ទៅ១៩៧៨ ខ្ញុំរស់នៅតែក្នុង ក្ដាវ៉ាសឡាន ហើយមានភារៈឃ្លាំមើលសត្វមាន់ ។ បើខ្ញុំបានរិះគន់ដល់ពួកមេដឹកនាំ ហើយមិនបានទៅស្លាប់នៅទួលស្លែង នោះគឺជាសំណាងរបស់ខ្ញុំហើយ», ស្រង់ចេញពី The Quality of Mercy - By William Shawcross, p.337) ។

★★★ លោកឈាន-វ៉មក៏ដូចលោកជួន-មុម គឺជាមេក្លោងយៀកមិញ ដែលបានយកសង្គ្រាមមកដុតស្រុកខ្មែរ ព្រមទាំងជាអ្នកបង្កើតរបបប៉ុល-ពត ។ មុននឹងរត់ចូលព្រៃ មេខ្មែរក្រហមដែលមានឈ្មោះថា អៀង-សារី, សាឡុត-សរ, ខៀវ-សំផន, ហ៊ូ-នឹម, ហ៊ូ-យន់... បានទៅស្នាក់អាស្រ័យនៅផ្ទះឈាន-វ៉មគ្រប់ៗគ្នា ។ ដូច្នេះឈាន-វ៉ម មិនមែនជាជនរងគ្រោះនៃថ្ងៃ១៧មេសាទេ... គឺជាមហាចោរដែលភ្លាត់ចំណាប់ ត្រូវរបួសឆេះរលាកនឹងអគ្គីភ័យ ដែលខ្លួនឯងជាអ្នកបានរៀបចំ (Les apprentis-sorciers) ។

❑

❑ ❑

# មុខការរបស់លោកឈាន-វ៉ម គឺការបង្វែងដាន

លោកឈាន-វ៉ម ហើយនិងលោកសឺន-សាន ជាអ្នកស្នេហាជាតិក្លែងក្លាយ (ជាអ្នកស្នេហាជាតិយួន មិនមែនស្នេហាជាតិខ្មែរនោះទេ) ។ ក្នុងឯកសារបារាំង Essai sur la Démocratie du Cambodge par Philippe Preschez- p.7 បានសរសេរថា កាលពីសម័យអាណានិគមបារាំង ប្រើតែជនជាតិយួនប៉ុណ្ណោះ យកមកធ្វើក្របខ័ណ្ឌអ្នករាជការថ្នាក់កណ្ដាល ដើម្បីត្រួតត្រាលើក្បាលជនជាតិខ្មែរ ៖

«ជាការពិត ពួកអាណានិគមមិនបានរវីរវល់បង្កើតឲ្យមានក្របខ័ណ្ឌនៃពួកជនដែលមានជាតិកំណើតក្នុងស្រុកនោះទេ ។ រដ្ឋការថ្នាក់លើបានត្រូវជនជាតិបារាំងកា

ន់ទៅហើយ ។ ចំណែករដ្ឋការថ្នាក់មធ្យម បានត្រូវប្រគល់ឲ្យជនជាតិយួន ដែលពួកបារាំងចូលចិត្តបង្ហាត់បង្រៀន ដោយព្រោះមានគោលដៅផ្សេងៗ... ជាជាងណែនាំបង្ហាត់បង្ហាញជនជាតិខ្មែរឲ្យចេះធ្វើការជាក្របខ័ណ្ឌ ។ ម្យ៉ាងទៀត អព្ភូតហេតុសង្គមបែបដូចនេះ មិនមែនតែនៅប្រទេសកម្ពុជានោះទេ ។ នៅក្នុងគោលគំនិតចក្រពត្រាធិរាជ, ពួកអាណានិគមមិនសូវរវីរវល់នឹងសភាពការណ៍ទូទៅនោះទេ ម្ល៉ោះហើយពួកគេបង្កើតក្របខ័ណ្ឌអ្នកចេះដឹង ដោយយោងទៅតាមគំនិតនេះឯង ដោយគ្មានយកចិត្តទុកដាក់អំពីលក្ខណៈទឹកដីនិងជាតិសាសន៍ផ្សេងៗ ៖ គឺនៅក្នុងប្រការនេះហើយ បានជាគេឃើញពួកឥណ្ឌាត្រូវយកមកប្រើប្រាស់ជាក្របខ័ណ្ឌរដ្ឋបាលនៅភូមា, ពួកចិននៅប្រទេសម៉ាឡេ, ពួកយួននៅកម្ពុជានិងលាវ ។ ចំណែកពួកជនជាតិខ្មែរវិញ សឹងតែជាទូទៅបានត្រូវគេយកទៅបញ្ចូលក្នុងក្របខ័ណ្ឌថ្នាក់ទាបជាទីបំផុត ដែលចំណាត់ការមានលក្ខណៈចាំបាច់ចៀសវាងមិនបាន (ស្មៀនស្មេរ,គូលី, ប្លង់តុង) ។ ដោយគេបង្ហាត់បង្រៀនឲ្យបំពេញតែកិច្ចការបន្ទាប់បន្សំ ពួកជនជាតិខ្មែរដ៏ភាគច្រើនលើសលប់ បានបង្ហាញនូវកង្វះសមត្ថភាពដ៏ជាក់ស្តែង ក្នុងប្រការបង្កើតអ្នកចេះដឹង ដែលជាសេចក្តីត្រូវការរបស់ប្រទេសជាតិ ។

★★★ យោងតាមអត្ថបទខាងលើនេះ យើងឃើញថា ពួកអាណានិគមបារាំងបានយកអ្នកចេះដឹងយួនយកមកធ្វើឲ្យរាំងស្ទះបញ្ញារបស់ជនជាតិខ្មែរទាំងមូល, តើធ្វើម្តេចឲ្យកម្ពុជាមានការលូតលាស់ស្មើវៀតណាមទៅបាន ? ជាឧទាហរណ៍ធំបំផុត បារាំងបានយកស្តេចយួនម្នាក់ឈ្មោះ «រាំងជួន» មានអំណាចដូចទ្រឿង-មិញយ៉ាំងឲ្យមកត្រួតត្រាលើក្បាលស្តេចខ្មែរអស់ពីជំនាន់រាជ្យស្តេច ៖ គឺស្តេចស៊ីសុវត្ថិនិងស្តេចមុនីវង្ស...។ ដូច្នេះអង្គការកំពូលលើរបស់ខ្មែរ គឺជាអង្គការរបស់យួន, គឺជាអង្គការ «ភ្នែកម្ចាស់» តែជាភ្នែករបស់យួន... បញ្ញាបាធីនៅកំពូលលើទាំងប៉ុន្មាន សុទ្ធសឹងតែជារបស់យួនទាំងអស់... តើរាំងជួនជាជនជាតិយួន ត្រូវការអ្វីទៅដណ្តើមទឹកដីកម្ពុជាក្រោមមកឲ្យខ្មែរវិញនោះ ? ខ្មែរយើងច្រើនគ្នាណាស់ដៀលខ្មែរគ្នាឯង ដែលរៀនភាសាបារាំងថាជាមនុស្សវង្វេងជាតិ ។ ប៉ុន្តែអ្នកដែលមានភ័ព្វវាសនាបានរៀនសូត្រភាសាបារាំង កាលពីសម័យអាណានិគម (ក្រៅពីពូជស្តេច) គឺសុទ្ធសឹងតែជាអ្នកស្នេហាជាតិយួន ។ ពួកអ្នកស្នេហាជាតិខ្មែរចេះបារាំងតិចតួចណាស់ ម្ល៉ោះហើយពេលដែលបារាំងផ្ទេរទឹកដីកម្ពុជាក្រោមឲ្យទៅវៀតណាម ក៏គ្មានខ្មែរណាដឹងដែរ ឬក៏ដឹងហួសពេលវេលាទៅហើយ ! ។

★★★ ពួកក្រុមដែលចេះភាសាបារាំងជ្រៅជ្រះជាងគេបំផុត កាលពីសម័យអាណានិគម ក៏គឺពូជពង្សវង្សត្រកូល រាំងជួន នេះឯង ។ ជួន-មុមជាកូនរបស់រាំងជួន មានឋានៈជាវិស្វករពហុបច្ចេកទេស Ingénieur Polytechnique ឋានៈមួយដែលសូម្បីតែជនជាតិបារាំងក៏ពិបាកដណ្តើមយកដែរ ។ ជួន-ប្រសិទ្ធ ជាវិស្វករចេញពី Ecole Centrale, ជួន-ជឿនជាវេជ្ជបណ្ឌិត (សព្វថ្ងៃរស់នៅជាមួយអៀង-សារី និង

ខៀវ-សំផននៅឡើយ), ឈាន-វ៉ម (កូនប្រសាររបស់វាំងជួន) បានសិក្សាអក្សរសាស្ត្របារាំងជាប់សញ្ញាប័ត្រ Licencié Es-Lettres, នៅក្នុងទសវត្សរ៍១៩៤០, សឺន-សាន (ទ្រៀង-មីញយ៉ាំងជំនាន់ថ្មី ដែលបានចូលមកក្នុងដែនដីប្រទេសកម្ពុជា តាំងពីឆ្នាំ១៩៣៦... ក្នុងគោលបំណងមកធ្វើជាស្តេចយួន ត្រួតត្រាលើក្បាលស្តេចខ្មែរ បន្តតំណែងពីវាំងជួន) បានប្រឡងជាប់សញ្ញាប័ត្រជាន់ខ្ពស់ផ្នែកពាណិជ្ជកម្មនៅប្រទេសបារាំង តាំងពីឆ្នាំ១៩៣២មកម្ល៉េះ Diplôme des Hautes Etudes Commerciales ពោលគឺនៅក្នុងសម័យមួយ ដែលប្រទេសខ្មែរមិនទាន់មានវិទ្យាល័យ សំរាប់ថ្នាក់មធ្យមសិក្សាប័ត្រនោះផង (គួរកត់សំគាល់ថា អ្នកទាំងអស់គ្នាខាងលើនេះ ឥតចេះភាសាខ្មែរទេ ចេះត្រឹមតែនិយាយ តែឥតចេះភាសាសរសេរទេ, ហើយចំណែកលោកសឺន-សាន សូម្បីតែនិយាយខ្មែរក៏មិនត្រូវជ្រុងផង) ។

★★★ នៅក្នុងឆ្នាំ១៩៤៩ ព្រះករុណា នរោត្តម-សីហនុ បានបញ្ជូនលោកសឺន-សានហើយនិងលោកឈាន-វ៉ម ទៅទាមទារទឹកដីកម្ពុជាក្រោមពីបារាំង ។ ប៉ុន្តែអ្នកទាំងពីរនេះ ជាបញ្ញាជនអ្នកស្នេហាជាតិយួនដ៏កំពូល... តើពួកគេត្រូវការអ្វីមកបំរើផលប្រយោជន៍របស់ជនជាតិខ្មែរទៅវិញនោះ ? ម្ល៉ោះហើយពួកគេបានត្រឹមតែដើរតួបង្វែងដានតែប៉ុណ្ណោះ... គឺបង្វែងដានទម្លាក់ទោសកំហុសទៅលើបារាំង និងទៅលើស្តេចសីហនុ ដើម្បីឲ្យជនជាតិខ្មែរវង្វេងវង្វាន់ ! ។ ម៉្យាងវិញទៀត ១៩៤៩ វាហួសពេលវេលាទាមទារកម្ពុជាក្រោមទៅហើយ... គឺអង្គរបានក្លាយទៅជាបាយរួចទៅហើយ... ដោយបារាំងបានស៊ីញេដីកម្ពុជាក្រោម ឲ្យស្តេចបាវដាយរួចទៅហើយ ។ ការផ្ទេរដំណោក (រវាងបារាំង-យួន) បានប្រព្រឹត្តទៅនៅក្នុងឆ្នាំ១៩៤៨... ដូច្នេះការសេពមេថុនធម៌នៅក្នុងឆ្នាំ១៩៤៩ គ្រាន់តែជាការបង្គ្រប់កិច្ច ជាទង្វើ«បង្គ្រប់ដៃជើង» ឬគ្រាន់តែជាការបង្វែងដាន ឲ្យជនជាតិខ្មែរបែកបាក់គ្នាតែប៉ុណ្ណោះ ។

នៅក្នុងឯកសាររបស់លោកឈាន-វ៉ម (ទំព័រទី១) បានសរសេរដូច្នេះថា ៖

«ទង្វើបត់បែនរបស់បារាំងក្នុងប្រការបោះបង់កម្ពុជាក្រោមឲ្យទៅវៀតណាម

«ដើម្បីប្រឈមមុខតទល់នឹងហូ-ជីមិញ ដែលកំពុងតែកាន់កាប់ទីក្រុងហាណូយ ក្នុងឋានៈជាចៅហ្វាយម្ចាស់ បន្ទាប់ពីការចុះចាញ់របស់ជប៉ុននៅក្នុងឆ្នាំ១៩៤៥ រដ្ឋាភិបាលបារាំងបាននឹកស្មានថាអាចរួចខ្លួន ដោយលើកយកអតីតព្រះចៅអធិរាជបាវ-ដាយ ដែលកាលនោះបានក្លាយទៅ «ពលរដ្ឋវិញធុយ» មកតែងតាំងជាប្រមុខរដ្ឋាភិបាលមួយនៅភាគខាងត្បូង ហៅថា «រដ្ឋាភិបាលរបស់ព្រះករុណាបាវដាយ» ។ ម៉្យាងវិញទៀត (<u>កកន</u> ៖ កន្លែងនេះជាបញ្ហាសំខាន់ណាស់ តែលោកឈាន-វ៉មសរសេរបែបរំភើយ ហាក់ដូចជាបញ្ហាតូចតាច ដោយប្រើពាក្យថា«ម៉្យាងវិញទៀត») ម៉្យាងវិញទៀត រដ្ឋាភិបាលបារាំងក៏បានចុះហត្ថលេខា នៅក្នុងខែមករា១៩៤៨ ជាមួយបាវដាយ ទៅលើ«សន្ធិសញ្ញានៃឆកអាឡុង» (Les accords de la Baie d'Along) ដែលទទួលស្គាល់អំពីគោលការណ៍បង្រួបបង្រួមអាណាខេត្តយួនទាំងបី (L'union

des 3 Ky ៖ គឺតុងកឹង, អណ្ណាម, កូសាំងស៊ីន) ។

★★★ ពុំមានខ្មែរអ្នកស្នេហាជាតិណាម្នាក់ដឹងអំពីសន្ធិសញ្ញាបារាំង-យួនថៃ «ឆកអាឡុង» នៅក្នុងឆ្នាំ១៩៤៨នោះទេ ចុះហេតុអ្វីបានជាលោកឈាន-វ៉ុមដឹង ?? គឺមកពីគាត់ជាជនជាតិយួន !! ហេ ! ហេ ! ឆ្នាំ១៩៤៨ ឈាន-វ៉ុមជានាយករដ្ឋមន្ត្រីខ្មែរ ម្ដេចគាត់មិនថាអីថាវ៉ាន់បានមួយម៉ាត់ផង ? បើបារាំងយល់ព្រមកាត់ដីកម្ពុជាក្រោមឲ្យទៅយួននៅក្នុងឆ្នាំ១៩៤៨ទៅហើយ... លោកសឺន-សានហើយនិងលោកឈាន-វ៉ុម ទើបបានមកភ្ញាក់រលឹកនៅក្នុងឆ្នាំ១៩៤៩ តើវាបានផលប្រយោជន៍អ្វីដែរ ?

★★★ លោកឈាន-វ៉ុមបានសរសេរថា ជាទង្វើបត់បែនរបស់បារាំង ដើម្បីបោះបង់កម្ពុជាក្រោមឲ្យទៅយួន»... តាមពិតគឺជាទង្វើបត់បែនរបស់ជនជាតិយួន... តាមពិតគឺជាទង្វើបត់បែនរបស់ឈាន-វ៉ុម ហើយនិងសឺន-សាន ។ ក្នុងប្រការបោះបង់ទឹកដីកម្ពុជាក្រោមឲ្យទៅយួន គឺជនជាតិយួនជាអ្នកបានចំណេញ ។ នៅគ្រប់ឧក្រិដ្ឋកម្មអ្វីក៏ដោយ អ្នកដែលបានចំណេញនោះហើយ គឺជាអ្នកធ្វើ ។ ក្បាលនរណាសក់របស់អ្នកនោះ ! ។

★★★ យើងនិយាយថា បារាំងកាត់ដីខ្មែរឲ្យទៅយួន គឺជាការមិនសមរម្យទាល់តែសោះ ។ មុនពេលបារាំងមកដល់កម្ពុជា... គឺជាសម័យទ្រឿង-មិញយ៉ាំង, ក្នុងរាជ្យម្ចាស់ក្សត្រីអង្គម៉ី (១៨៣៤-១៨៤១) (មុនព្រះអង្គដួង), គឺជាសម័យដែលយួនបានដាក់ឈ្មោះភ្នំពេញថាជា «ណាំយ៉ាំង» ។ កាលនោះសៀមបានកាត់យកខែត្របាត់ដំបង, កំពង់ធំ, សៀមរាប, ស្ទឹងត្រែងបាត់អស់ទៅហើយ... ចំណែកយួនបានមកវាតទីតាំងបន្ទាយនៅខេត្តកំពត, ភ្នំពេញ និងពោធិសាត់ ។ ក្នុងសម័យនោះ កុំថាឡើយស្រុកមួយដុំ សូម្បីកូនទូកមួយនៅជ្រោយចង្វារ ក៏ខ្មែរមិនសល់ដែរ ។ យួនមកដុតវត្តអារាម វាយកំទេចព្រះពុទ្ធបដិមាករ ប្រមូលច្បាប់ក្រមគម្ពីរឯកសាររបស់ខ្មែរ «បោះចោលទៅក្នុងទន្លេមេគង្គ ឡើងអណ្ដែតត្រៀបត្រា ខ្មៅងងឹត គួរឲ្យអាណោចអធម៌ពន់ពេក» ។

«ព្រះរាជាណាចក្រខ្មែរកាលសម័យនោះ ឋិតនៅក្រោមព្រះរាជក្រឹត្យមួយនៃស្ដេចអណ្ណាម បានត្រូវគ្រប់គ្រងដោយមន្ត្រីជាន់ខ្ពស់បីរូបគឺ ទ្រឿង-មិញយ៉ាំង, ផាំ-យ៉ាំងដឿង ហើយនិងត្រាំង-យ៉ាំងណាង ដែលទទួលបន្ទុកកាន់កាប់ស្រុកខ្មែរដោយមានជំនួយ ពីក្រុមរដ្ឋមន្ត្រីនិងចៅហ្វាយខេត្តខ្មែរ ។

«កាលនោះទីក្រុងភ្នំពេញ បានបាត់បង់ទាំងឈ្មោះខ្លួនឯងទៀតទៅហើយ គឺបានទទួលឈ្មោះថ្មីថា ត្រាំងតាយ ឬត្រាំងណាំយ៉ាំង (ទីក្រុងភ្នំ)...

«លោកវេស៊ីដង់អណ្ណាម (ទ្រឿង-មិញយ៉ាំង) នឹកស្មានថាខ្លួនឯងខ្លាំងពូកែសំបើមណាស់ ជាពិសេសនឹកថាខ្លួនជាចៅហ្វាយម្ចាស់នៃផែនដីនេះទៅហើយ ក៏បានទាមទារឲ្យក្រុមមន្ត្រីខ្មែរទាំងឡាយស្លៀកពាក់ជាយួន ហើយទុកសក់បួង ព្រមទាំងផ្ដល់មុខងារជាយួន ដល់ក្រុមអ្នករាជការជាន់ខ្ពស់ទាំងអស់ មិនត្រឹមតែប៉ុណ្ណោះ ថែ

មទាំងបានដាក់រេស៊ីដង់អណ្ណាម (មេកម្មាភិបាល) នៅជាប់ជាមួយចៅហ្វាយខេត្តគ្រប់ៗរូប ដើម្បីឈ្លបមើលសកម្មភាពនិងការគ្រប់គ្រងរបស់ពួកគេ (កកន ៖ បើយើងធ្វើការប្រៀបធៀបសម័យទ្រឿង-មិញយ៉ាំង មកកាលសម័យសម្តេចសីន-សាន គឺមិនសូវខុសគ្នាប៉ុន្មានទេ  ពីព្រោះនៅក្នុងកាលសម័យ«សង្គមរាស្ត្រនិយម»របស់ស្តេចសីហនុ ក៏មានមេកម្មាភិបាលយួនត្រួតត្រាលើក្បាលខ្មែរទាំងអស់ ៖ សម្តេចយួនស្រីស្រីង្គារចៅហ្វាប៉ែន-នុត ត្រួតលើរាជការខ្មែរជាទូទៅ ។ ប៉ែន-នុតមានចៅកែចិនម្នាក់ជាអ្នកចិញ្ចឹម ផ្តល់លុយកាក់ ស្រីញី និងអាភៀន ឈ្មោះ ចៅ-ខុង ។ គឺចៅខុងនេះហើយ ដែលធ្វើឲ្យទំនិញឡើងថ្លៃនិងចុះថ្លៃស្រេចនឹងចិត្តនៅប្រទេសកម្ពុជា, ចំណែក អេង-ហ៊ុន នាយកមន្ទីរប្តូរប្រាក់ គ្រាន់តែមានឋានៈជាគូលី... ទៅណាមកណាឃ្មួរកាតាបឲ្យចៅខុងតែប៉ុណ្ណោះ ។ សម្តេចយួនបវរសេដ្ឋាមហាសម្បត្តិសីន-សាន ត្រួតត្រាកាន់កាប់សេដ្ឋកិច្ច និងកិច្ចការបរទេសទាំងអស់... គឺសីន-សាននេះហើយដែលបោះពុម្ពប្រាក់៥០០រៀលទាំងហឹបៗ នៅថ្មីថែស មិនទាន់ទាំងកាត់ផង យកទៅដាក់បំពោកនៅក្នុងជំរំយៀកកុងនិងមេមត់... សម្តេចចក្រីយួនញឹក-ជូឡុង ជាអ្នកត្រួតត្រាលើកងទ័ពទាំងអស់... លោកនល់-នល់ជាមេទ័ពពិតមែន តែញឹក-ជូឡុងជាចៅហ្វាយខេត្តកំពង់ចាម, លោកលន់-នល់មានឋានៈត្រឹមតែជាចៅហ្វាយស្រុកព្រែកពោធិតែប៉ុណ្ណោះ) ។

★★★ លោក Adhémare Leclère បានសរសេរបន្តមកទៀតថា ៖«ទ្រឿង-មិញយ៉ាំងចង់បានច្រើនជាងនេះទៅទៀត  ពោលគឺជននេះកំពុងតែយលសប្តិយលសូងចង់ឲ្យស្រុកខ្មែរបាត់បង់លក្ខណៈជាខ្មែរទាំងស្រុង  ដោយកែប្រែដូរឈ្មោះស្រុកភូមិខ្មែរ ឲ្យទៅជាយួនមិនឲ្យមានសេសសល់... (ដកស្រង់ចេញពី Histoire du Cambodge par Adhémar Leclère- pages 421-422) ។

★★★ យោងតាមឯកសារខាងលើនេះ  ប្រសិនបើមហាអំណាចបារាំងមិនបានធ្វើដំណើរមកដល់  ឥណ្ឌូចិននោះទេ...  នោះប្រទេសកម្ពុជានឹងត្រូវរលាយបាត់សូន្យសុងពីផែនទីពិភពលោក  តាំងពីសតវត្សទី១៩មកម្ល៉េះ...  នៅពេលនោះទន្លេមេគង្គនឹងក្លាយទៅជាព្រំប្រទល់ចុងក្រោយនៃប្រទេសវៀតណាមនិងថៃជាប្រាកដ  ។ ដូច្នេះ  គឺជនជាតិសៀមហើយនិងយួនជាខ្មាំងសត្រូវជាមួយបារាំង  មិនមែនជនជាតិខ្មែរទេ ។ បារាំងដែលបានមកកាន់កាប់ ឬមកគាំពារដែនដីកម្ពុជាចំនួន១០០ឆ្នាំ (Protectorat)...  គឺបានមកប្រឆាំងនឹងមហិច្ឆិតារបស់ជនជាតិយួនហើយនិងសៀម  មិនឲ្យពួកនេះលេបត្របាក់ដែនដីសេសសល់ចុងក្រោយនៃមហានគរខ្មែរទាំងប៉ុន្មានរហូតរលាយរលត់បាត់ឈ្មោះបោះសម្លេងដូចស្រុកចំប៉ា...  ពោលគឺបានបន្សល់ទុកកម្ពុជាកណ្តាលមួយដែរ  សំរាប់ជាមោទនភាព  (ទីក្រុងអង្គរ)  និងជាទីកន្លែងសំរាប់ជនជាតិខ្មែរ រស់នៅរហូតមកដល់សព្វថ្ងៃនេះ...។ ដូច្នេះពេលដែលបារាំងបានមកកាន់កាប់កម្ពុជាចំនួន១០០ឆ្នាំ បារាំងមិនបានធ្វើឲ្យជនជាតិខ្មែរបាត់បង់ទឹកដីនោះទេ ផ្ទុ-

យទៅវិញ គឺបានធ្វើឲ្យខ្មែរចំណេញទឹកដី !!

★★★ ដូច្នេះ ពួកជនដែលបាននាំអាទិឲ្យខ្មែរធ្វើចំបាំងជាមួយបារាំង តាំងពីពេលបារាំងមកដល់ មានអាចារ្យស្វា ពោធិកំបោរ ហើយបន្ទាប់មកទៀត មានឈាន-វ៉ម ហើយនិងសឺន-សាន គឺសុទ្ធតែជាជនជាតិយួន ។ គឺពួកយួនវាបោកប្រាជ្ញាជនជាតិខ្មែរ ឲ្យអារមែកឈើ ដែលជាទ្រនុំរបស់ខ្លួនឯង !!

❑

❑ ❑

# ជនជាតិយួនបានណែនាំខ្មែរទាមទារឯករាជ្យ ជាឧបាយកលដើម្បីរំដោះទឹកដីកម្ពុជាក្រោមទៅយួន

នៅក្នុងឯកសារ ៖ Essai sur la Démocratie au Cambodge របស់លោក Philippe Preschez នៅទំព័រទី១១ មានសរសេរថា ៖

«ព្រឹត្តិការណ៍នៃខែមិនា១៩៤៥ មានលំនាំដូចជាខ្សែភ្លើងឆក់ ដែលបណ្តាលឲ្យប្រទេសកម្ពុជាមានការភ្ញាក់រឭកចំពោះអ្វីៗដែលទាក់ទងនឹងសតិសម្បជញ្ញៈរបស់ជាតិ ។ នៅថ្ងៃទី៩មិនា, កងទ័ពជប៉ុនបានកំចាត់រដ្ឋការបារាំង និងកងទ័ពបារាំងអស់រលីងពីប្រទេសកម្ពុជា ។ ដោយក្លាយទៅជាចៅហ្វាយម្ចាស់ផ្តាច់មុខនៅពីលើគ្រប់សភាពការណ៍... ជប៉ុនក៏បានអនុញ្ញាតឲ្យប្រទេសកម្ពុជា ទទួលឯករាជ្យតាមផ្លូវទ្រឹស្តី (Une indépendance théorique: គឺឯករាជ្យក្លែងក្លាយ) ។ ហើយនៅថ្ងៃ១២មិនា ព្រះករុណានរោត្តម-សីហនុក៏បានថ្លែងប្រកាសចោទប្រកាន់ (លែងទទួលស្គាល់) ទៅលើគ្រប់សន្ធិសញ្ញា ដែលធ្វើឡើងក្នុងសម័យរដ្ឋការប្រូតិចតូរ៉ាបារាំង ព្រមទាំងប្រកាសឯករាជ្យនៃប្រទេសកម្ពុជា ដោយថ្លែងអញ្ជើញប្រជាជាតិខ្មែរទាំងមូលឲ្យកត់សម្គាល់ពីទង្វើដ៏មហាឧឡារិកនេះ» ។

★★★ យើងគួរពិនិត្យមើលឲ្យច្បាស់, ការប្រកាសឯករាជ្យនេះ មិនមែនជាទង្វើរបស់លោកសឺង-ង៉ុកថាន់ទេ... គឺជាទង្វើរបស់សីហនុ ។ ការប្រកាសឯករាជ្យនៅពេលនោះ គឺជាអំពើចង្រៃឧបទ្រពមួយដ៏ធំណាស់ចំពោះប្រទេសកម្ពុជា ពីព្រោះថាជប៉ុនទើបនឹងបានកាត់ទឹកដីខេត្តបាត់ដំបងនិងខេត្តសៀមរាបឲ្យទៅសៀម... បើយើងប្រកាសឯករាជ្យនៅពេលនោះ គឺយើងបានទទួលឯករាជ្យមួយ ដែលគ្មានដីខេត្តបាត់ដំបងនិងសៀមរាប ។ ការទាត់ចោលសន្ធិសញ្ញាទាំងអស់ដែលធ្វើឡើងជាមួយបារាំង ក៏ជាអំពើល្ងង់ខ្លៅហៅមិនឮមួយទៀតរបស់ស្តេចខ្មែរ ពីព្រោះជាការបោះបង់ទឹកដីខេត្តបាត់ដំបង, សៀមរាប និងស្ទឹងត្រែង ដែលបារាំងបានដណ្តើមពីសៀមយកមកឲ្យខ្មែរ នៅក្នុងសន្ធិសញ្ញានៃឆ្នាំ១៩០៤ និង១៩០៧ ។

នៅក្នុងឯកសារ Histoire du Cambodge របស់លោក A. Dauphin Meunier ទំព័រ១០៩ និង១១០ បានសរសេរថា ៖

«ស៊ីសុវត្ថិហើយនិងសហាការបារាំង-ខ្មែរ

«នៅក្នុងរាជ្យរបស់ព្រះបាទស៊ីសុវត្ថិ (១៩០៤-១៩២៧) ដែលប្អូនប្រុសបន្ទាប់របស់ហ្លួងនរោត្តម, ដោយសន្ធិសញ្ញាស៊ីញ៉េជាមួយសៀមក្នុងឆ្នាំ១៩០៤ និង១៩០៧ ប្រទេសបារាំងក៏បានផ្តល់ទ្រង់ទ្រាយដល់ប្រទេសកម្ពុជាឡើងវិញ ដូចដែលធ្លាប់មានមុនអំពើក្បត់របស់នាយបែន (កកន ៖ នាយបែន ឬចៅហ្វាបែន ជាជីលួតជីលារបស់ខ្មែរប៉ុក... មានប៉ុក-ធួន, ប៉ុក-ធឿន, ប៉ុក-ម៉ូណា, ប៉ុក-ដើសកុមារ...ប៉ុក-ថន គឺជាសែខ្មែរក្រហមទាំងអស់ ! ពូជសាច់ថ្លៃរបស់រាំងជួន !) ម៉្លោះហើយតែក្នុងមួយរំ-ពេជ ប្រទេសកម្ពុជាក៏មានទំហំរីកធំឡើងវិញមួយជាពីរ ។ ព្រំដែនខាងជើងក៏ថយទៅនៅលើជួរភ្នំដងរែក និងប្រទេសលាវ ។ ទោះជាយ៉ាងនេះក្តី ប្រទេសសៀមនៅរក្សាកាន់កាប់ខេត្តខ្មែរទាំងអស់ ដែលស្ថិតនៅខាងត្បូងនៃតំបន់សេមូន (សីរមាន់?) និងខាងកើតនៃដងស្ទឹងប្រាជិន (ប្រាជិនបូរី) ដែលនៅទីនោះ ប្រជាជននៅជនបទទាំងអស់ សុទ្ធសឹងតែជាជនជាតិខ្មែរ មានចំនួន៥០០,០០០នាក់ ។

«អន្តរាគមន៍បារាំងនេះ ជាជំនួយមួយធំណាស់សំរាប់កម្ពុជានិងប្រជាពលរដ្ឋខ្មែរ ។ អន្តរាគមន៍នេះបានបញ្ចប់ការវាតទឹកដី ដែលបានកាត់ពុះបែងចែកព្រះរាជាណាចក្រចំនួន៤សតវត្សមកហើយ... មិនត្រឹមតែប៉ុណ្ណោះ គឺបានថែរក្សាប្រជាជនខ្មែរ ឲ្យរស់នៅគង់វង្សបន្ទាប់ពីសង្គ្រាម, វិវាទផ្ទៃក្នុង, ទុរភិក្ស និងជម្ងឺអាសន្នរោគបានពង្រួញពីចំនួន១៥លាននាក់ កាលពីសម័យមហានគរ ឲ្យនៅសល់តែ៤០០,០០០នាក់ (គឺប្រជាជនខ្មែរកណ្តាល ពេលដែលបារាំងរៀបចំស្រុកឡើងវិញ) ។

★★★ បន្ទាប់ពីសេចក្តីប្រកាសឯករាជ្យពីបារាំង នៅថ្ងៃទី១២មិនា១៩៤៥ នៅពេលដែលបារាំងកំពុងទ្រោមខ្លួន ដោយត្រូវជប៉ុនសម្លាប់អស់, ស្តេចនរោត្តម-សីហនុត្រូវប្រឈមនឹងការរលាយអន្តរធានពីរយ៉ាង ៖ ប្រសិនបើជប៉ុនឈ្នះបារាំងនៅពេ-លចប់សង្គ្រាម នោះស្តេចខ្មែរនឹងត្រូវបាត់បង់ទឹកដីខេត្តបាត់ដំបង, សៀមរាប និងស្ទឹងត្រែងជាស្ថាពរ ប៉ុន្តែបើសភាពការណ៍ក្រឡាប់ ហើយបារាំងប្រែជាឈ្នះជ-ប៉ុនវិញ ហើយបើស្តេចសីហនុនៅរក្សារាជសម្បត្តិនិងកម្ពុជាកណ្តាលបានឡើងវិញនោះ... ត្រូវចាត់ទុកថាប្រទេសបារាំង មានធម៌មេត្តាពេកណាស់ហើយ... ប៉ុន្តែរឿងដែនដីកម្ពុជាក្រោម កុំត្រូវសង្ឃឹមថាយកបានវិញឲ្យសោះ !!

★★★ ដូច្នេះឯករាជ្យដែលស្តេចសីហនុបានប្រកាស នៅថ្ងៃទី១៤មិនា១៩៤៥ នោះ... មិនមែនជាឯករាជ្យចំណោញទេ តែជាឯករាជ្យបាត់បង់ទឹកដី ។ ចំណែកជនដែលណែនាំស្តេចឲ្យប្រកាសឯករាជ្យនេះ គឺលោកអគ្គមហាសេនា អ៊ុំង-ហ៊ី... ដែលបន្តតំណែងបណ្តោះអាសន្នពី វាំងជួន ។ គិតសព្វៗទៅ សំបុកឃ្មុនដែលសម្ងំស៊ីរូងផ្ទៃក្នុងព្រះរាជវាំងខ្មែរ ក៏មានលំនាំដូចតែសំបុកកណ្តៀរដែលស៊ីសសរផ្ទះ... កាលណាគេមើលឃើញក្បាល គេមើលឃើញកន្ទុយ... កាលណាគេមើលឃើញកន្ទុយ គេមើលឃើញក្បាល ។ អ៊ុំង-ហ៊ី នេះជាចៅហ្វាយរបស់ប៉ែន-នុត និងជាឪពុកក្មេក

របស់លោកចេង-ហេង ។ លោកចេង-ហេងធ្លាប់បានប្រាប់ខ្ញុំផ្ទាល់ ថាលោកប៉ែន-នុតជាឪពុកធម៌របស់គាត់... ចំណែកប្រពន្ធលោកចេង-ហេង (កូនស្រីរបស់អ៊ឹង-ហ៊ី) ធ្លាប់បានប្រាប់ខ្ញុំថា គាត់ត្រូវជាប្អូនជីដូនមួយនឹងអ្នកម្នាងម៉ូនិក ។ ក្រោយថ្ងៃ១៨មិនា១៩៧០ គេអាចមើលឃើញលោកចេង-ហេង ជាប្រមុខរដ្ឋខ្មែរនៅខាងលន់-នល់... ចំណែកប៉ែន-នុត ជារដ្ឋមន្ត្រីទី១ខ្មែរក្រហមនៅខាងស្ដេចសីហនុនិងអ្នកម្នាងម៉ូនិក, ក៏ដូចតែឈាន-វ៉ំមនៅខាងលន់-នល់... ចំណែកជួន-មុមនៅខាងប៉ុល-ពតដូច្នោះ ។ ពួកសំបុកយួនទាំងនេះ គឺលេងល្បែងយកជនជាតិខ្មែរមកលាបពណ៌ឲ្យខ្មែរសម្លាប់ខ្មែរទាល់តែផុតពូជទេតើ... ដើម្បីឲ្យកម្ពុជាក្លាយទៅជាស្រុកដែលគ្មានខ្មែរ ស្រួលឲ្យយួនចូលមករស់នៅ...។

★★★ សីហនុប្រកាសឯករាជ្យបង់ខាតទឹកដី នៅថ្ងៃ១២មិនា១៩៤៥ មិនទាន់គ្រប់គ្រាន់ទេ ពួកសំបុកយួននៅក្នុងព្រះរាជវាំង ថែមទាំងរៀបចំទម្លាក់ទោសកំហុសទៅលើលោកសឺង-ង៉ុកថាន់ថែមទៀត ។ នេះជាការថ្លិនភ្លែកក្រឡៃប្រវត្តិសាស្ត្ដដ៏កាចសាហាវបំផុត ពីសំណាក់ជនជាតិយួន ។ នៅក្នុងឯកសារ Essai sur la Démo-cratie du Cambodge នៅទំព័រទី១២ មានសរសេរថា ៖

«...ក៏ប៉ុន្តែនៅពេលនោះ ពួកជនជាតិចប៉ុនក៏បានណែនាំឲ្យលោកសឺង-ង៉ុកថាន់ត្រឡប់មកពីតូក្យូវិញ នៅដើមខែឧសភា (១៩៤៥) ។ នៅដើមខែមិថុនា លោកសឺងង៉ុកថាន់ ក៏បានត្រូវតែងតាំងជារដ្ឋមន្ត្រីក្រសួងការបរទេស ។ យោងតាមក្រមនៃថ្ងៃទី៧មិថុនា ព្រះអង្គម្ចាស់មុនីរេត ក៏បានត្រូវតែងតាំង (ដោយជប៉ុន) ឲ្យធ្វើជាទីប្រឹក្សានៃរាជរដ្ឋាភិបាល ដោយមានសម្លេងសំរេចនៅក្នុងគណរដ្ឋមន្ត្រី (កកន ៖ សម្ដេចក្រុមព្រះស៊ីសុវត្ថិ-មុនីរេត ក៏ជាកូនប្រសាររបស់វាំងជួន ដូចលោកឈាន-វ៉ំមដែរ... ចំណែកគណរដ្ឋមន្ត្រីបេស់អ៊ឹង-ហ៊ី ក៏ជាកូនចៅរបស់វាំងជួនទាំងអស់គ្នា ដូច្នេះព្រឹត្តិការណ៍ទាំងប៉ុន្មាន ដែលកើតឡើងក្នុងសម័យនោះ ក៏មិនមែនជាទង្វើរបស់លោកសឺង-ង៉ុកថាន់ទេតែជាទង្វើរបស់សំបុកកណ្ដៀរយួននៅក្នុងព្រះរាជវាំងទាំងអស់)។

យោងតាមឯកសារដដែល «២ខែក្រោយមក, ថ្ងៃទី១៨សីហា, លោកសឺង-ង៉ុកថាន់បានបញ្ជាឲ្យចាប់ខ្លួនមន្ត្រីទាំងអស់ ហើយតាំងខ្លួនលោកជានាយករដ្ឋាភិបាលទី១នៃប្រទេសកម្ពុជាឯករាជ្យ» ។ (កកន ៖ តាមពិតលោកសឺង-ង៉ុកថាន់ឥតមានចាប់រដ្ឋមន្ត្រីណាម្នាក់ទេ គ្រាន់តែធ្វើឲ្យស្ដេចភ័យ រត់ទៅពួននៅវត្តលោកប៉ុណ្ណោះ...អ្នកចំណាត់ការគឺខ្មែរក្រោមម្នាក់ដែលមានឈ្មោះថា ចៅ-សែនកុសល ហៅឈុំ យោងតាមសៀវភៅ Souvenirs doux et amers របស់ស្ដេចសីហនុ, ចំណែកក្រុមរដ្ឋមន្ត្រីរបស់លោកសឺង-ង៉ុកថាន់ គឺសុទ្ធសឹងជាភ្នាក់ងាររបស់ វាំងជួន ដែលបានណែនាំលោកសឺង-ង៉ុកថាន់ ឲ្យប្រឆាំងជាមួយបារាំង រួចហើយក៏បានណែនាំបារាំង ឲ្យចាប់ខ្លួនលោកទៅដាក់គុកនៅព្រៃនគរវិញទៅ ។ សមាសភាពមានដូចតទៅ ៖ សឺង-ង៉ុកថាន់ រដ្ឋមន្ត្រីទី១ ទទួលបន្ទុកក្រសួងការបរទេស, នរោត្តម-ម៉ុងតាណា កសិកម្ម

ស៊ុំ-ហ៊ាង មហាផ្ទៃ, វ៉ាំរ-កាមែល ធម្មការ, ប៉ាជ-ឈឺន ក្រសួងផ្គត់ផ្គង់ភស្តុភារ, ពីទូ-ដឹម៉ុងតេរ៉ូ យុត្តិធម៌, ឃីម-ទិត ក្រសួងការពារជាតិ... ឃីម-ទិត ជាក្រុមតស៊ូជាមួយលោកសឺង-ង៉ុកថាន់ តែបែរទៅជាទៅហៅបារាំង ឲ្យមកចាប់លោកសឺង-ង៉ុកថាន់ទៅវិញ ដោយទម្លាក់ទោសកំហុសទៅលើសីហនុ, ជូឡុង ក្រសួងសេដ្ឋកិច្ចជាតិ, ប៉ែន-នុត ក្រសួងហិរញ្ញវត្ថុ... ដូច្នេះក្រុមទាំងអស់នេះ មិនមែនជាក្រុមលោកសឺង-ង៉ុកថាន់ទេ តែជាក្រុមរបស់ស៊ីសុវត្ថិ-មុនីរេត ដែលជាកូនប្រសាររបស់ វាំងជួន) ។

នៅក្នុងឯកសារដដែល លោក Philippe Preschez បានសរសេរថា ៖ «នៅក្នុងគណរដ្ឋមន្ត្រីរបស់សឺង-ង៉ុកថាន់ មានឈ្មោះ ប៉ាជ-ឈឺន ដែលបានប្រោះកាសែត «នគរវត្ត» ឲ្យរស់ឡើង បន្ទាប់ពីពួកជប៉ុនបានរំដោះលោកឲ្យចេញពីគុក (កកន ៖ លោកប៉ាជ-ឈឺន ជាបងជីដូនមួយរបស់លោកឌុក-រ៉ាស៊ី ។ ទៅថ្ងៃមុខទៅ លោកប៉ាជ-ឈឺន ណែនាំលោកសឺង-ង៉ុកថាន់ ឲ្យរត់ចូលពួកឥស្សរៈ... រួចបន្ទាប់មក ប៉ាជ-ឈឺនក៏រត់ទៅចូលខាងបារាំង ដើម្បីចាប់ពួកឥស្សរៈទាំងនោះវិញ) ។ «បន្ទាប់ពីការចុះចាញ់នៃប្រទេសជប៉ុននៅថ្ងៃទី១៥មិនា១៩៤៥, លោកសឺង-ង៉ុកថាន់ក៏បានប្រកាសអំពីគោលបំណងរបស់លោក ដើម្បីបន្តរក្សាឯករាជ្យរបស់ប្រទេសខ្មែរ ។ សារពត៌មាន «Cambodge» («កម្ពុជា»ជាភាសាបារាំង) បានបោះផ្សាយអត្ថបទដ៏ហឹង្សាក្រៃលែង សរសេរដោយជនជាតិអណ្ណាម ដែលថ្កោលទោសទៅលើបារាំង ហើយដែលលើកសរសើរតម្កើងអំពីសេចក្តីស្នេហាជាតិមោះមុតរបស់ជនជាតិខ្មែរ» ។ កាលណាយួនសរសើរខ្មែរ នោះយួនកំពុងតែសម្លាប់ជាតិខ្មែរហើយ ។

⋆⋆⋆ ទាំងអស់នេះជាភស្តុតាងជាក់ស្តែង ស្ទើរតែបណ្តាលឲ្យខ្វាក់ភ្នែក ថាជនជាតិយួនជាអ្នកណែនាំខ្មែរឲ្យទាមទារឯករាជ្យ ដែលបង់ខាតទឹកដី ។ បើយើងវិលត្រឡប់មកពិនិត្យឯកសាររបស់ ឈាន-វ៉ំម វិញ, គឺនៅក្នុងឆ្នាំ១៩៤៩ លោកសឺន-សាននិងលោកឈាន-វ៉ំម មិនបានទៅទាមទារដែនដីកម្ពុជាក្រោមឲ្យខ្មែរទេ តែបាននាំគណប្រតិភូខ្មែរ ឲ្យទៅទាមទារឯករាជ្យពីបារាំង... ឲ្យមានមុខយួន... គឺជាឯករាជ្យដែលខ្មែរត្រូវខាតបង់ទឹកដីកម្ពុជាក្រោម ។ នៅក្នុងទំព័រទី១នៃឯកសាររបស់លោកលោកឈាន-វ៉ំមបានសរសេរថា ៖ «ការចរចាដើម្បីបង្កើតសន្ធិសញ្ញាខ្មែរ-បារាំងដើម្បីជំនួយលក្ខន្តិកៈសំរុះសំរួលបណ្តោះអាសន្ន Modus Vivendis

«នៅឯសហភាពបារាំងឯណោះ, នៅក្នុងកិច្ចប្រជុំការងារមួយ នៃថ្ងៃទី១៤មេសា១៩៤៩,<ក្រុមប្រឹក្សាខ្មែរ>មានស៊ឹម-វ៉ាំរ, ថុន-អ៊ុក និងសុក-ឆុង ហើយនិងម្ចាស់ក្សត្រិយ៍ពីងពាង-យុគន្ធរ ដោយមានការគាំទ្រពី<ទីប្រឹក្សជាមិត្ត>ដ៏ច្រើន (?) បានបង្ហាញនូវគំរោងការមួយ ដែលអញ្ជើញឲ្យរដ្ឋាភិបាលបារាំង ធ្វើការចរចាជាមួយនឹងរដ្ឋាភិបាលខ្មែរ អំពីសន្ធិសញ្ញាមួយ ដែលសមស្របនឹងមាត្រា៦១នៃរដ្ឋធម្មនុញ្ញបារាំង ដែលអនុញ្ញាតឲ្យជំនួសលក្ខន្តិកៈព្រមព្រៀងបណ្តោះអាសន្ន le Modus Vivendi នៃថ្ងៃ៧មករា១៩៤៦ ដែលជាគំនាបនៃរដ្ឋការឃោឋាបារាំងមកលើប្រទេសកម្ពុជា

ដែលត្រឡប់មកឥណ្ឌូចិនវិញ បន្ទាប់ពីមានការចុះចាញ់ពីសំណាក់ប្រទេសជប៉ុន» ។

★★★ បើយើងពិនិត្យមើលអត្ថបទរបស់លោកឈាន-វ៉ម យូរទៅ យើងត្រូវឈឺក្បាល ព្រោះមើលមិនឃើញទំព័រណាសោះ ដែលឈាន-វ៉មបានទាមទារទឹកដីកម្ពុជាក្រោមមកឲ្យជាតិខ្មែរ ។ វាទៅជាឃើញមានការទាមទារ ឲ្យយកសន្ធិសញ្ញាបារាំង-ខ្មែរ ឲ្យមកជំនួស Modus Vivendi ! ។

★★★ ប៉ុន្តែពេលដែលបារាំងបានចាប់លោកសឺង-ង៉ុកថាន់ទៅឃុំឃាំង (១៦តុលា១៩៤៥) បារាំងបានតែងតាំងសម្តេចក្រុមព្រះ ស៊ីសុវត្ថិ-មុនីរេត (កូនប្រសាររបស់វាំងជួន) ជានាយករដ្ឋមន្ត្រី ដោយបានរក្សាទុកសមាសភាពនៃគណរដ្ឋមន្ត្រីរបស់លោកសឺង-ង៉ុកថាន់ទាំងអស់ ដែលសុទ្ធសឹងជាភ្នាក់ងាររបស់វាំងជួន ។ សម្តេចមុនីរេតក៏បានតែងតាំងគណៈកម្មាធិការសិក្សាចំរុះបារាំង-ខ្មែរ ដែលមានភារកិច្ចនិពន្ធលក្ខន្តិកៈសំរុះសំរួលបណ្តោះអាសន្ន Modus Vivendi, គំរោងរដ្ឋធម្មនុញ្ញ និងគំរោងសន្ធិសញ្ញាបារាំង-ខ្មែរ ដែលជាកំរោងរដ្ឋបាលនិងភូមិសាស្ត្រ សំរាប់ការបោះឆ្នោតនៅកម្ពុជាកណ្តាល ដែលនៅក្នុងនោះគ្មានដែនដីកម្ពុជាក្រោមទេ... ពោលគឺគំរោងទាមទារឯករាជ្យពីបារាំង ដោយខាតបង់ទឹកដីកម្ពុជាក្រោម ។ ក្រុមនិពន្ធដែលសរសេរគំរោងទាំងបីនេះជាភាសាបារាំង... គឺជាក្រុមនិពន្ធតែមួយដែលមានសមាសភាពដូចតទៅ ផ្នែកខាងខ្មែរ ៖ ព្រះអង្គម្ចាស់ស៊ីសុវត្ថិ-មុនីពង្ស, ឃឹម-ទិត, ញឹក-ជូឡុង, ចាន់-ណាក់ និងឈាន-វ៉ម ។ ខាងបារាំងមាន Saint Mleux, Ponge, Roux, Boiffier, Mary...។ ឃើញថាក្រុមនេះជាក្រុមត្រូវរ៉ូវគ្នាចាក់ទឹកមិនលេចជាមួយនឹងបារាំងទេតើ !!...

តើហេតុអ្វីបានជាមានការទាមទារឲ្យយកលក្ខន្តិកៈនៃសន្ធិសញ្ញាបារាំង-ខ្មែរមកជំនួស Modus Vivendi ទៅវិញ ដែលជាអត្ថបទតែមួយ សរសេរដោយក្រុមនិពន្ធតែមួយ ហើយដែលមានន័យដូចគ្នាតែមួយ គឺការទាមទារឯករាជ្យពីបារាំងដោយខាតបង់ទឹកដីកម្ពុជាក្រោម ។

❑

❑ ❑

<u>សេចក្តីបញ្ចប់</u> ៖ រដ្ឋសភាបារាំងបានបោះឆ្នោតសំរេចជាផ្លូវការ (នៅថ្ងៃទី២១ ឧសភា ១៩៤៩) ផ្ទេរទឹកដីកម្ពុជាក្រោមទៅឲ្យវៀតណាម ។ លោកឈាន-វ៉ម ក៏បានវិលត្រឡប់មកប្រទេសកម្ពុជាដោយដៃទទេ ដោយមិនខ្វីទាំងធ្វើសេចក្តីរាយការណ៍ឲ្យស្តេចសីហនុនោះផង ។ លោកឈាន-វ៉មបានដាក់ទោសកំហុស ទៅលើលោកយ៉ែម-សំបូរ ដែលបានកោះហៅលោកឲ្យវិលត្រឡប់មកវិញ... រកតែលោកសំរេចអ្វីមិនបាន «គឺជាការចាក់សម្លាប់ពីក្រោយខ្នង», លោកឈាន-វ៉មពោល ។ ប៉ុន្តែលោកយ៉ែម-សំបូរនេះ ជាកូនចៅរបស់វាំងជួនម្នាក់ទៀត ដែលបានធ្វើរដ្ឋប្រហារធម្មនុញ្ញក្នុងឆ្នាំ១៩៤៩ ដើម្បីលើកអំណាចបរិបូណ៌ថ្វាយព្រះកូណាននរោត្តម-សីហនុ គឺជា

ការខ្ចីដៃរបស់ស្ដេចប្រើ ដើម្បីចុះហត្ថលេខាទៅលើសន្ធិសញ្ញាបារាំង-ខ្មែរ ដោយគ្មានហត្ថលេខារបស់ប្រធានរដ្ឋសភា ពោលគឺលោកអៀវ-កើស ។ នេះជាឧបាយកលរបស់យួន ដើម្បីទម្លាក់ទោសនៃការបាត់បង់ទឹកដីកម្ពុជាក្រោម ទៅលើស្ដេចសីហនុតែប៉ុណ្ណោះ ។

★★★ ជាបន្ទាប់មក លោកឈាន-វ៉ំមធ្វើបុកជាអាក់អន់ស្រពន់ចិត្តនឹងស្ដេចសីហនុ ហើយរត់ទៅធ្វើការបំរើយួនយៀកកុង នៅក្នុងក្រុមហ៊ុនដឹកនាំចេញចូល (Import-Export) ដែលថ្ងៃមុខទៅមានឈ្មោះថា ក្រុមហ៊ុនរដ្ឋសូណិចស៊ីម (ឆ្នាំ១៩៦៤)។ នៅពេលនោះ ក្នុងនាមជាប្រធានអគ្គនាយក លោកឈាន-វ៉ំមក៏មានមុខមាត់ធ្វើជាមេដឹកនាំភស្តុភារឲ្យយៀកកុងជាផ្លូវការ ដោយសហការជាមួយនឹងមេខ្មែរយៀកមិញម្នាក់ទៀតឈ្មោះ លី-គឹមហេង (ជាអគ្គនាយកសូណិចស៊ីម ព្រមទាំងជាអ្នកកាន់ហឹបប្រាក់«សង្គមរាស្ត្រនិយម»របស់ស្ដេចសីហនុ)...រហូតដល់មេសា១៩៧៥ ខែវងកម្ម ឆ្នាំព្រាត់ប្រាស់ (!!) ។៚

❑ ❑

❑